*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ១១ អនក្រ
## ស្តីពីការប្តូរទីរួមខេត្តជាស្រុកនិងសង្កាត់ ឃុំ ក្នុងខេត្តកំពង់ចាម

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្តរបស់ខេត្តកំពង់ចាម មកជាស្រុកកំពង់ចាម ដែលមានទីតាំងរដ្ឋបាលសាលាស្រុកនៅភូមិទី ៨ ឃុំកំពង់ចាម ។

**មាត្រា ២ :** ត្រូវបានប្តូរសង្កាត់ចំនួន ៤ ចំណុះទីរួមខេត្ត មកជាឃុំចំនួន ៤ ចំណុះស្រុកកំពង់ចាមគឺ :

សង្កាត់ កំពង់ចាម មកជា ឃុំ កំពង់ចាម

សង្កាត់ វាលវង់ មកជា ឃុំ វាលវង់

សង្កាត់ សំបួរមាស មកជា ឃុំ សំបួរមាស

សង្កាត់ បឹងកុក មកជា ឃុំ បឹងកុក

**មាត្រា ៣ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

www.pheakdeylaw.com

**មាត្រា ៥ :** អនុក្រឹត្យនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៥*

**អនុក្រឹត្យលេខ ១២ អនក្រ**

**ស្តីពីការប្តូរឈ្មោះស្រុក ទីរួមខេត្ត**

**សង្កាត់ ក្នុងខេត្ត រតនគិរី**

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ :** ត្រូវបានប្តូរឈ្មោះស្រុក បានលុង មកជាស្រុក អូរជុំ ។

**មាត្រា ២ :** ត្រូវបានប្តូរឈ្មោះទីរួមខេត្ត របស់ខេត្តរតនគិរី មកជាស្រុក បានលុង ដែលមានទីតាំងរដ្ឋបាលសាលាស្រុក នៅភូមិទី ៣ ឃុំ ឡាបានសៀក ។

**មាត្រា ៣ :** ត្រូវបានប្តូរឈ្មោះសង្កាត់ចំនួនបីចំណុះទីរួមខេត្តមកជាឃុំចំនួនបីចំណុះស្រុក បានលុងគឺ :

- សង្កាត់ យក្ខឡោម មកជា ឃុំ យក្ខឡោម
- សង្កាត់ ឡាបានសៀក មកជា ឃុំ ឡាបានសៀក
- សង្កាត់ កៅស៊ូ មកជា ឃុំ កាចាញ ។

**មាត្រា ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

www.pheakdeylaw.com